## តុលាការកំពូលខោនធី **THURSTON**

## *Liang, et al. v. State of Washington Dep’t of Social & Health Services (DSHS), et al.*

ប្រសិនបើអ្នកជា ឬធ្លាប់ជាអ្នកផ្តល់សេវាជាបុគ្គល **(IP)** ដែលបានផ្តល់ការថែទាំផ្ទាល់ខ្លួនដល់អតិថិជនដែលម៉ោងថែទាំគិតថ្លៃរបស់ពួកគេត្រូវបានកាត់បន្ថយដោយ **DSHS** ដោយសារតែវិធាន “អត្ថប្រយោជន៍រួមចំណែក” អ្នកអាចទទួលបានការទូទាត់ប្រាក់ពីការរៀបចំសកម្មភាពនៅក្នុងថ្នាក់បាន។

*តុលាការបានផ្តល់ការអនុញ្ញាតសេចក្តីជូនដំណឹងនេះ។ នេះមិនមែនជាការអន្ទងពីមេធាវីនោះទេ។*

ការផ្សះផ្សានេះនឹងផ្តល់ទឹកប្រាក់ $116 លាន ដើម្បីទូទាត់សំណងទាមទារដោយអ្នកផ្តល់សេវាជាបុគ្គល (IP) ដែលបានផ្តល់ការថែទាំផ្ទាល់ខ្លួនទៅដល់អតិថិជនដែលម៉ោងថែទាំគិតថ្លៃរបស់ពួកគេត្រូវបានកាត់បន្ថយដោយ DSHS ដោយសារតែវិធាន “អត្ថប្រយោជន៍រួមចំណែក” នៅចន្លោះថ្ងៃទី 7 ខែមីនា ឆ្នាំ 2014 និង ថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2021។

ការផ្សះផ្សានេះគឺដោះស្រាយបណ្តឹងឱ្យចប់ថាតើ IPs ត្រូវបានគេបដិសេធការទូទាត់សំណងពេញសម្រាប់ចំនួនម៉ោងដែលបានធ្វើការដោយសារតែវិធានអត្ថប្រយោជន៍រួមចំណែក; ទូទាត់ប្រាក់ទៅឱ្យ IPs; ចៀសវាងហានិភ័យផ្សេងៗពីការបន្តបណ្តឹង; ទូទាត់ប្រាក់ទៅឱ្យ IPs ដូចជារូបអ្នក; និងបញ្ចេញ DSHS និងអ្នកការពារក្តីផ្សេងទៀតពីទំនួលខុសត្រូវ។

សិទ្ធិស្របច្បាប់របស់អ្នកត្រូវបានរងផលប៉ះពាល់ មិនថាអ្នកធ្វើសកម្មភាពឬអត់ទេ។ ចូរអានសេចក្តីជូនដំណឹងនេះដោយប្រុងប្រយ័ត្ន។ ព័ត៌មានច្រើនទៀតគឺអាចរកបាន នៅ www.IPWageSettlement.com។

### សិទ្ធិ និងជម្រើសស្របច្បាប់របស់អ្នកក្នុងការផ្សះផ្សារ

| | |
|---|---|
| មិនបាច់ធ្វើអ្វីទេ ហើយប្រសិនបើអ្នកទទួលបានសែក ចូរទៅដកប្រាក់ទៅ | បន្តនៅក្នុងបណ្តឹងនេះ។ បោះបង់សិទ្ធិជាក់លាក់នានា។<br>ដោយការមិនធ្វើអ្វី អ្នកនឹងនៅតែបន្តនៅក្នុងថ្នាក់។ ប្រសិនបើការផ្សះផ្សារត្រូវបានអនុម័ត ហើយអ្នកមានចំណែកក្នុងនោះ អ្នកនឹងទទួលបានសែក។ សូមមើលផ្នែក 9-13។ ប្រសិនបើអ្នកបើកសាច់ប្រាក់ ឬដាក់បញ្ញើនូវសែកនោះ អ្នកកំពុងតែផ្ទៀងផ្ទាត់ថា អ្នកបានធ្វើឱ្យអតិថិជនដែលរងផលប៉ះពាល់ដោយផ្តល់ជូនអតិថិជននូវការថែទាំមានចំនួនជាក់លាក់ ហើយមិនត្រូវបានគិតប្រាក់ឱ្យសម្រាប់សេវាកម្មទាំងនោះ។ ការផ្ទៀងផ្ទាត់នេះគឺមានលម្អិតនៅក្នុងផ្នែក 13 ខាងក្រោម។ ប្រសិនបើអ្នកមិនបើកសាច់ប្រាក់ពីសែកនេះទេ ចំនួនទឹកប្រាក់នោះនឹងត្រូវបានចែកចាយឡើងវិញទៅឱ្យ ដទៃទៀត ប៉ុន្តែអ្នកនៅតែបោះបង់សិទ្ធិរបស់អ្នកក្នុងការប្តឹង DSHS ដដែលសម្រាប់ការទាមទារដែលគ្របដណ្តប់ដោយការផ្សះផ្សារនេះ។ |
| ដកខ្លួនដោយខ្លួនឯង | ចេញពីបណ្តឹងនេះ។ មិនយកអត្ថប្រយោជន៍អ្វីពីវា។ រក្សាសិទ្ធិផ្សេងៗ។<br>ប្រសិនបើអ្នកដកខ្លួនដោយខ្លួនឯង ឬ “ជ្រើសរើសចេញ” ពីការផ្សះផ្សារនេះ  អ្នកនឹងមិនទទួលបានការទូទាត់ប្រាក់ផ្សះផ្សារនោះទេ។ ប៉ុន្តែអ្នកនឹងរក្សាសិទ្ធិណាមួយដែលអ្នកអាចត្រូវតែបន្តទាមទារប្រឆាំងនឹង DSHS ដាច់ដោយឡែក។ ដើម្បីជ្រើសរើសចេញ អ្នកត្រូវតែធ្វើសកម្មភាពត្រឹម ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022។ |
| ជំទាស់ | ប្រាប់តុលាការ ប្រសិនបើអ្នកមិនចូលចិត្តការផ្សះផ្សារនេះ។<br>ប្រសិនបីអ្នកមិនពេញចិត្តនឹងលក្ខខណ្ឌនៃការផ្សះផ្សារដែលបានស្នើសុំនេះទេ អ្នកអាចដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរជាមួយតុលាការ និង/ឬ បង្ហាងមុខនៅក្នុងតុលាការ ដើម្បីពន្យល់ពីការជំទាស់របស់អ្នក។ អ្នកមិនអាចជ្រើសរើសចេញផង និងជំទាស់នឹងការផ្សះផ្សារនេះផងបានទេ។ |

- សិទ្ធិ និងជម្រើសរបស់អ្នក និងកាលបរិច្ឆេទដល់កាលកំណត់ក្នុងការអនុវត្តពួកវា ត្រូវបានពន្យល់ក្នុងការជូនដំណឹងនេះ។
- តុលាការនៅតែត្រូវសម្រេចចិត្តថាតើគួរអនុម័តការផ្សះផ្សារនេះឬអត់។ ការទូទាត់ប្រាក់នឹងត្រូវបានធ្វើឡើង ប្រសិនបើតុលាការអនុម័តការផ្សះផ្សារនេះ និងបន្ទាប់ពីបណ្តឹងឧទ្ធរណ៍ទាំងឡាយត្រូវបានដោះស្រាយ។ សូមមានការអត់ធ្មត់។

**تتوفر نسخة من هذا الإشعار باللغة العربية على الموقع الإلكتروني www.IPWageSettlement.com.**
**یک نسخه از این اطلاعیه به زبان فارسی در** www.IPWageSettlement.com. **موجود است.**
**ਇਸ ਨੋਟਿਸ ਦਾ ਪੰਜਾਬੀ ਅਨੁਵਾਦ www.IPWageSettlement.com.'ਤੇ ਉਪਲਬਧ ਹੈ।** · **Версия этого Уведомления на русском языке доступна на www.IPWageSettlement.com.** · **Nuqulka Ogeysiiskan oo Af-Soomaali ah ayaa laga heli karaa www.IPWageSettlement.com.** · កំណែជា ភាសាខ្មែរ នៃសេចក្តីជូនដំណឹងនេះ គឺអាចរកបាននៅ **www.IPWageSettlement.com**។ · **Una versión en español de este aviso está disponible en www.IPWageSettlement.com.** · **Версія цього Повідомлення доступна українською тут www.IPWageSettlement.com..** · **Một phiên bản của Thông Báo này hiện có bằng Tiếng Việt tại www.IPWageSettlement.com.** · **此通知函的中文版位于www.IPWageSettlement.com.。** · 이 알림 버전은 **www.IPWageSettlement.com** 에서 한국어로 이용가능합니다. · **ਇਸ ਨੋਟਿ ਸ ਦਾ ਪੰਜਾਬੀ ਅਨੁਵਾਦ www.IPWageSettlement.com. 'ਤੇ ਉਪਲਬਧ ਹੈ।**

ព័ត៌មានមូលដ្ឋាន

**1.** តើហេតុអ្វីបានជាខ្ញុំទទួលបានការជូនដំណឹងនេះ?

អ្នកទទួលបានការជូនដំណឹងនេះ ដោយសារតែកំណត់ត្រានៃក្រសួងសង្គមកិច្ច និងសេវាសុខភាពរបស់ Washington បង្ហាញថាអ្នកគឺ ឬធ្លាប់ជាអ្នកផ្តល់សេវាបុគ្គល (IP) ដែលបានចុះកិច្ចសន្យាជាមួយ DSHS គ្រង់ចំនុចខ្លះ ចន្លោះថ្ងៃទី 7 ខែមីនា ឆ្នាំ 2014 និងថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2021 ដើម្បីផ្តល់សេវាថែទាំផ្ទាល់ខ្លួនសម្រាប់អតិថិជនដែលម៉ោងថែទាំគិតថ្លៃឈ្នួលរបស់ពួកគេត្រូវបានកាត់បន្ថយ ដោយសារតែ ដាក់ក្រុមស្ថានភាពរបស់អតិថិជនក្នុងការវាយតម្លៃ CARE ជា "អត្ថប្រយោជន៍រួមចំណែក" សម្រាប់យ៉ាងហោចណាស់កិច្ចការចំនួនមួយ។

តុលាការបានបង្គាប់បញ្ជាថាអ្នកត្រូវបានផ្ញើការជូនដំណឹងនេះ ដោយសារតែអ្នកមានសិទ្ធិដឹងអំពីការផ្សះផ្សារដែលបានស្នើសុំ និងសិទ្ធិ និងជម្រើសស្របច្បាប់របស់អ្នក មុនពេលតុលាការសម្រេចថាតើគួរអនុម័តការផ្សះផ្សារនេះឬយ៉ាងណា។ បណ្តឹងត្រូវបានស្គាល់ជា *Liang, et al. v. State of Washington, et al.*, No. 20-2-02506-34; គឺកំពុងតែរង់ចាំនៅក្នុងតុលាការកំពូល Washington សម្រាប់ខោនធី Thurston; និងត្រូវបាននាំមកដោយ IPs មួយចំនួន (ដែលបានសំដៅដល់ជា "ដើមបណ្តឹង" នៅក្នុងការជូនដំណឹងនេះ) ប្រឆាំងនឹងរដ្ឋ Washington, DSHS និងលេខាធិការ DSHS (សំដៅរួមគ្នាជា "DSHS" នៅក្នុងការជូនដំណឹងនេះ)។

**2.** តើបណ្តឹងនេះគឺអំពីអ្វីខ្លះ?

ដើមបណ្តឹងចោទថា ចាប់ពី ថ្ងៃទី 7 ខែមីនា ឆ្នាំ 2014 រហូតដល់ថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2021, DSHS មិនបានទូទាត់ប្រាក់ឱ្យ IPs មួយចំនួននូវប្រាក់ឈ្នួលទាំងអស់ដែលពួកគេត្រូវបានជំពាក់ឡើយ។ ដើមបណ្តឹងនិយាយថា នេះបានកើតឡើង នៅពេល DSHS បានកាត់បន្ថយចំនួនម៉ោងថែទាំដែលគិតថ្លៃឱ្យ ដោយសារតែខ្លួនបានរកឃើញថា IP និងអតិថិជនម្នាក់ ឬអតិថិជនច្រើនទៀតនាក់នៅក្នុងគ្រួសារតែមួយបានចែករំលែកនៅក្នុងអត្ថប្រយោជន៍នៃកិច្ចការថែទាំផ្ទាល់ខ្លួនមួយចំនួនដែលបានបំពេញដោយ IP ដូចជាការចម្អិនម្ហូប ការដើរទិញទំនិញ ការងារផ្ទះ ឬការផ្គត់ផ្គង់អុស។ បណ្តឹងស្វែងរកការទូទាត់ត្រឡប់ និងការខូចខាតលើប្រាក់ផ្សេងទៀត ក្រោមកិច្ចសន្យារដ្ឋ និងច្បាប់ប្រាក់ឈ្នួលសម្រាប់ការងារដែលដើមបណ្តឹងអះអាងថា IPs បានធ្វើការដោយមិនបង់ប្រាក់ឈ្នួលឱ្យ។

DSHS បដិសេធថាខ្លួនមិនបានបំពានច្បាប់ណាមួយ ឬបានធ្វើអ្វីមួយខុសឆ្គងឡើយ។

**3.** តើសកម្មភាពថ្នាក់នៃការផ្សះផ្សារគឺជាអ្វី?

សកម្មភាពថ្នាក់គឺជាបណ្តឹងមួយប្រភេទដែលដើមបណ្តឹងដែលមានឈ្មោះ ប្តឹងសម្រាប់ខ្លួនពួកគេផ្ទាល់ និងសម្រាប់អ្នកដទៃផងដែរដែលមានស្ថានភាពស្រដៀងគ្នានេះ។ ក្នុងករណីនេះ ដើមបណ្តឹងគឺមានដូចជា IPs បីនាក់, Sylvia Liang, Manuel Brito, និង Shazia Anwar ។ IPs ដទៃទៀតគឺត្រូវបានស្គាល់ជា "សមាជិកថ្នាក់" ។ នៅក្នុងសកម្មភាពថ្នាក់ តុលាការមួយដោះស្រាយបញ្ហាផ្សេងៗសម្រាប់សមាជិកថ្នាក់ លើកលែងសម្រាប់អ្នកដែលដកខ្លួនពួកគេចេញពីថ្នាក់។

តុលាការបានបញ្ជាក់ករណីនេះជាសកម្មភាពថ្នាក់តែសម្រាប់គោលបំណងនៃការផ្សះផ្សារដែលបានស្នើប៉ុណ្ណោះ។ តុលាការមិនបានសម្រេចចិត្តថាតើករណីនេះគួរតែត្រូវបានបញ្ជាក់ជាសកម្មភាពថ្នាក់សម្រាប់គោលបំណងនៃការសម្រេចភាពសមនឹងទទួលបាននៃការទាមទាររបស់ដើមបណ្តឹងនោះទេ។ ប្រសិនបើតុលាការមិនបានអនុញ្ញាតការអនុម័តស្ថាពរនៃការផ្សះផ្សារនេះសម្រាប់ហេតុផលណាមួយនោះទេ នឹងមិនមានថ្នាក់ផ្សះផ្សារមួយឡើយ ហើយភាគីទាំងនោះនឹងត្រឡប់ទៅជំទាស់នឹងករណីនេះវិញ។ ដែលគ្របដណ្តប់ដោយការផ្សះផ្សារនេះ គឺត្រូវបានស្គាល់ជា "សមាជិកថ្នាក់ផ្សះផ្សារ" លើកលែងតែអ្នកដែលបានដកខ្លួនពួកគេចេញពីថ្នាក់ផ្សះផ្សារនេះ។

**4.** ហេតុអ្វីបានជាមានការផ្សះផ្សារ?

ភាគីទាំងពីរជឿថា ពួកគេនឹងឈ្នះនៅក្នុងតុលាការ ប៉ុន្តែតុលាការមិនបានចាត់វិធានគាំទ្រភាគីណាមួយឡើយ។ ភាគីទាំងពីរបានយល់ព្រមចំពោះការផ្សះផ្សារ ដើម្បីចៀសវាងថ្លៃចំណាយ ការពន្យារពេល ហានិភ័យ និងការមិនប្រាកដប្រជាដែលទាក់ទងនឹងការកាត់ក្តី និងបណ្តឹងឧទ្ធរណ៍។ ពួកគេបានធ្វើដូច្នេះ បន្ទាប់ពីការស៊ើបអង្កេតដ៏យូរ និងការផ្លាស់ប្តូរព័ត៌មានគ្នា។ សមាជិកថ្នាក់ផ្សះផ្សារដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្រោមការគណនាដែលបានរៀបរាប់ក្នុងផ្នែកទី 10 ខាងក្រោម ទទួលបានការទូទាត់សំណង។

ដើមបណ្តឹង និងមេធាវីរបស់ពួកគេ (ទីប្រឹក្សាថ្នាក់) គិតថាការផ្សះផ្សារគឺស្ថិតក្នុងផលប្រយោជន៍ល្អបំផុតនៃសមាជិកថ្នាក់ផ្សះផ្សារទាំងអស់ និងថាលក្ខខណ្ឌនៃការផ្សះផ្សារគឺស្មើភាព សមហេតុផល និងគ្រប់គ្រាន់។

## តើនរណានៅក្នុងការផ្សះផ្សារនេះ?

**5.** តើនរណាជាផ្នែកនៃថ្នាក់ផ្សះផ្សារនេះ?

ថ្នាក់ផ្សះផ្សារត្រូវបានកំណត់ជា៖ “IPs បច្ចុប្បន្ន និងអតីតទាំងអស់ដែលបានចុះកិច្ចសន្យាជាមួយ DSHS ក្នុងការផ្តល់សេវាថែទាំផ្ទាល់ខ្លួន សម្រាប់អតិថិជនដែលចំនួនម៉ោងក្នុងផ្ទះរបស់ពួកគេត្រូវបានកាត់បន្ថយដោយសារតែ DSHS តាមរយៈភ្នាក់ងាររបស់ខ្លួន បានដាក់ក្រុមអតិថិជនក្នុងការវាយតម្លៃ CARE ថាមានស្ថានភាព “អត្ថប្រយោជន៍រួមចំណែក” ដោយជាប់ទាក់ទងនឹង មួយ ឬច្រើន។”

**6.** តើខ្ញុំជាផ្នែកនៃថ្នាក់ផ្សះផ្សារនេះមែនទេ?

មែនហើយ លុះត្រាតែអ្នកដកខ្លួនឯងចេញដោយជ្រើសរើសចេញ (មើលផ្នែក 15–16)។ អ្នកកំពុងតែទទួលបានការជូនដំណឹងនេះ ដោយសារតែ កំណត់ត្រារបស់ DSHS បង្ហាញថាអ្នកបានធ្វើការឱ្យយ៉ាងហោចណាស់អតិថិជនមួយនាក់ដែលចំនួនម៉ោងថែទាំដែលផ្តល់សិទ្ធិអនុញ្ញាតរបស់ DSHS ពួកគេត្រូវបានកាត់បន្ថយអំឡុងរយៈពេលថ្នាក់ ដោយសារតែ DSHS បានដាក់ក្រុម “ស្ថានភាព” របស់អតិថិជន នៅក្នុងការវាយតម្លៃ CARE ជា “អត្ថប្រយោជន៍រួមចំណែក” សម្រាប់យ៉ាងហោចណាស់មួយកិច្ចការថែទាំផ្ទាល់ខ្លួន។

**7.** តើដូចម្តេច ប្រសិនបើខ្ញុំមិនទទួលបានការជូនដំណឹងដោយផ្ទាល់ ប៉ុន្តែគិតថាខ្ញុំជាសមាជិកម្នាក់នៃថ្នាក់ផ្សះផ្សារនេះ?

ប្រសិនបើអ្នកមិនទទួលបានការជូនដំណឹងនេះដោយផ្ទាល់ទេ ប៉ុន្តែគិតថាអ្នកបានធ្វើការឱ្យអតិថិជនរបស់ DSHS ដែលចំនួនម៉ោងថែទាំ ដែលផ្តល់សិទ្ធិអនុញ្ញាតរបស់ពួកគេត្រូវបានកាត់បន្ថយអំឡុងរយៈពេលថ្នាក់ ដោយសារតែ DSHS បានវាយតម្លៃអតិថិជនថាមាន “អត្ថប្រយោជន៍រួមចំណែក” សូមទាក់ទងអ្នករដ្ឋបាលការផ្សះផ្សារ តាមលេខ 888-964-0102។

## អត្ថប្រយោជន៍នៃការផ្សះផ្សារ—អ្វីដែលអ្នកទទួលបាន

**8.** តើការផ្សះផ្សារនេះផ្តល់ជូនអ្វីខ្លះ?

DSHS បានយល់ព្រមបង់ប្រាក់ $116,068,000 ដែលនឹងត្រូវបានប្រើសម្រាប់ការទូទាត់ប្រាក់ទៅដល់សមាជិកថ្នាក់ផ្សះផ្សារ ចំណែកពន្ធលើប្រាក់បៀវត្សរ៍របស់ DSHS និងរបស់ IPs, កម្រៃឈ្នួលមេធាវីរបស់ទីប្រឹក្សាថ្នាក់ និងការចំណាយផ្សេងៗ, ថ្លៃចំណាយនានានៃរដ្ឋបាលការផ្សះផ្សារ និងការជូនដំណឹង និងដែលអាចអនុវត្តបាន បំណុលសហជីព។

**9.** តើការទូទាត់ប្រាក់របស់ខ្ញុំមានចំនួនប៉ុន្មាន?

ការទូទាត់ប្រាក់ដែលប៉ាន់ស្មានរបស់អ្នកគឺ [ផ្តល់ជូនដោយអ្នកគ្រប់គ្រង]។ ដូចទៅនឹងសមាជិកថ្នាក់ផ្សះផ្សារដទៃទៀតទាំងអស់ ការទូទាត់ប្រាក់ជាបុគ្គលរបស់អ្នកគឺជាចំណែកតាមសមាមាត្រ (ឬជាសមាមាត្រ) នៃការផ្សះផ្សារដែលផ្អែកលើចំនួនម៉ោងដែលដើមបណ្តឹងអះអាងថា អ្នកបានធ្វើការដោយគ្មានការគិតប្រាក់ឱ្យអំឡុងរយៈពេលថ្នាក់ និងអត្រាប្រាក់ឈ្នួលដែលអាចអនុវត្តបានសម្រាប់ចំនួនម៉ោងទាំងនោះ។

**10.** តើការទូទាត់ប្រាក់របស់ខ្ញុំត្រូវបានគណនាយ៉ាងដូចម្តេច?

ភាគីនានាបានយល់ព្រមលើវិធីសាស្ត្រគណនាការទូទាត់ប្រាក់សម្រាប់សមាជិកថ្នាក់ផ្សះផ្សារនីមួយៗ ជាលក្ខណៈបុគ្គល ដោយផ្អែកលើទិន្នន័យនៅក្នុងកំណត់ត្រារបស់ DSHS។ ទិន្នន័យបង្ហាញពីអតិថិជនណាមួយដែល DSHS បានវាយតម្លៃថាមាន “អត្ថប្រយោជន៍រួមចំណែក,” IPs ដែលបានថែទាំសម្រាប់អតិថិជនទាំងនោះ ចំនួនម៉ោងដែលផ្តល់ការអនុញ្ញាតជាច្រើនត្រូវបានកាត់បន្ថយ និងមិនបានគិតប្រាក់ឱ្យ ដោយសារតែ ការដាក់ក្រុមស្ថានភាព “អត្ថប្រយោជន៍រួមចំណែក”, អ្នកផ្តល់សេវាដែលបានគិតប្រាក់ឱ្យដែលត្រូវបានចាត់តាំងទៅកិច្ចការ “អត្ថប្រយោជន៍រួមចំណែក” និងចំនួនប៉ុន្មានដែលរដ្ឋបានគិតប្រាក់ឱ្យអ្នកផ្តល់សេវាទាំងនោះ។

ចំណែកនៃការផ្សះផ្សាយដែលប៉ាន់ស្មានរបស់អ្នកត្រូវបានគណនាដោយចែកការបង់ប្រាក់ត្រលប់ដែលប៉ាន់ស្មានរបស់អ្នកដោយ ចំនួនបង់ប្រាក់ត្រលប់សរុបសម្រាប់សមាជិកថ្នាក់ផ្សះផ្សារទាំងអស់ និងគុណនឹងចំនួននោះដោយ $105 លាន។ ទឹកប្រាក់ $105 លានគឺជាមូលនិធិផ្សះផ្សារសរុបដកនឹងចំនួនដែលរក្សាត្រលប់ដើម្បីបង់សម្រាប់ចំណែកពន្ធលើប្រាក់បៀវត្សរ៍របស់ DSHS,

កម្រៃឈ្នួលរបស់មេធាវីរបស់ទីប្រឹក្សាថ្នាក់ និងថ្លៃចំណាយផ្សេងៗ, ថ្លៃចំណាយលើរដ្ឋបាលការផ្សះផ្សារ និងការជូនដំណឹងថ្នាក់ និងការចំណាយផ្សេងទៀត។ ការបង់ប្រាក់ត្រលប់សម្រាប់ការគណនានេះគឺជាចំនួនម៉ោងដែលមិនបានគិតប្រាក់ឱ្យដោយសារតែ "អត្ថប្រយោជន៍រួមចំណែក" ត្រូវបាន គុណនឹងអត្រាប្រាក់ឈ្នួលដែលអាចអនុវត្តបាន (រួមទាំងធ្វើការលើសម៉ោង ដែលអាចអនុវត្តបាន) ដោយគ្មានការខូចខាត ឬផលប្រយោជន៍ទ្វេដងឡើយ។ ប្រសិនបើអ្នកផ្តល់សេវាជាច្រើននាក់សម្រាប់អតិថិជនដូចគ្នាត្រូវបានរងផលប៉ះពាល់ដោយ "អត្ថប្រយោជន៍រួមចំណែក" នៅក្នុងខែដូចគ្នា ចំនួនម៉ោងដែលមិនបានគិតប្រាក់ឱ្យត្រូវបានចែកជាសមាមាត្រក្នុងចំណោមពួកគេ។

ប្រសិនបើសមាជិកថ្នាក់ផ្សេងទៀតមិនបើកសាច់ប្រាក់ចេញពីសែករបស់ពួកគេទេ ឬថ្លៃចំណាយលើការផ្សះផ្សារផ្សេងទៀតមានតម្លៃតិចជាងការប៉ាន់ស្មាន អ្នកអាចទទួលបានរហូតដល់ការទូទាត់ពីរបន្ថែមដែលនឹងជាចំណែកសមាមាត្ររបស់អ្នកនៃមូលនិធិការផ្សះផ្សារសរុបដែលនៅសល់ បូកនឹងការប្រាក់ដែលបានកើនឡើងលើមូលនិធិ។

**11.** ហេតុអ្វីបានជាការទូទាត់ប្រាក់ដែលប៉ាន់ស្មានរបស់ខ្ញុំច្រើន ឬតិចជាងរបស់អ្នកផ្សេង?

មូលនិធិទូទាត់នេះត្រូវបានបែងចែកក្នុងចំណោមសមាជិកថ្នាក់ការផ្សះផ្សារដោយផ្អែកលើភាគរយតាមសមាមាត្រ (*ឧ.* ជាសមាមាត្រ) ភាគរយនៃមូលនិធិ ដោយគិតគូរពីការខូចខាតបុគ្គលដែលបានប៉ាន់ស្មានរបស់ IP នីមួយៗជាផ្នែកនៃការខូចខាតទាំងមូល។ ចំនួនទឹកប្រាក់នៃការផ្សះផ្សាបុគ្គលនឹងប្រែប្រួលដោយផ្អែកលើកត្តាដូចជារយៈពេល IP ធ្វើការនៅចន្លោះថ្ងៃទី 7 ខែមីនា ឆ្នាំ 2014 និងថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2021 ចំនួនម៉ោងថែទាំដែលបានកាត់បន្ថយពីម៉ោងដែលបានអនុញ្ញាតដោយសារតែ "អត្ថប្រយោជន៍រួមចំណែក" (ដែលអាចខុសគ្នាផ្អែកលើម៉ោងថែទាំសរុបរបស់អតិថិជន និង "អត្ថប្រយោជន៍រួមចំណែក" ប៉ុន្មាន DSHS បានសម្រេចថាមាន អត្រាប្រាក់ឈ្នួលរបស់ IP និងថាតើអត្រាម៉ោងបន្ថែមត្រូវបានអនុវត្តឬទេ។

**12.** ហេតុអ្វីចំណែកដែលបានប៉ាន់ស្មានរបស់ខ្ញុំអាចជាសូន្យ?
អ្នកអាចជាសមាជិកថ្នាក់ការផ្សះផ្សារ ប៉ុន្តែមិនជំពាក់ប្រាក់ណាមួយឡើយ ប្រសិនបើកំណត់ត្រារបស់ DSHS បង្ហាញអ្នកផ្តល់សេវាផ្សេងទៀត ហើយមិនមែនអ្នក ត្រូវបានចាត់តាំងឱ្យបំពេញកិច្ចការ "អត្ថប្រយោជន៍រួមចំណែក" នៅក្នុងផែនការថែទាំរបស់អតិថិជន ប្រសិនបើ DSHS មិនជ្រើសរើស "អត្ថប្រយោជន៍រួមចំណែក" ជា "ស្ថានភាព" សម្រាប់អតិថិជន ឬប្រសិនបើ DSHS បានវាយតម្លៃអត្ថប្រយោជន៍ ដែលបានចែករំលែកខាងក្រៅរយៈពេលនៃថ្នាក់។

**13.** តើលក្ខខណ្ឌសំខាន់ផ្សេងទៀតនៃការផ្សះផ្សារមានអ្វីខ្លះ?
ការផ្ទៀងផ្ទាត់៖ តាមការដកសាច់ប្រាក់ ឬការដាក់ប្រាក់ការបង់ប្រាក់ផ្សះផ្សាររបស់អ្នក អ្នកកំពុងផ្ទៀងផ្ទាត់ថា៖

1. អ្នកជា ឬធ្លាប់ជា IP សម្រាប់អតិថិជនដែលមានការអនុញ្ញាតសេវាកម្មថែទាំផ្ទាល់ខ្លួនតាមផ្ទះប្រចាំខែត្រូវបានកាត់បន្ថយ ដោយសារតែ "អត្ថប្រយោជន៍រួមចំណែក" ដែលអ្នកបានផ្តល់។
2. អ្នកបានផ្តល់សេវាកម្មថែទាំផ្ទាល់ខ្លួនដល់អតិថិជននោះដែលត្រូវបានរួមបញ្ចូលក្នុងផែនការថែទាំរបស់អតិថិជនសម្រាប់យ៉ាងហោចណាស់ចំនួនអត្ថប្រយោជន៍រួមដែលបានកែតម្រូវម៉ោងដែលបានចង្អុលបង្ហាញនៅក្នុងទិន្នន័យរបស់ DSHS តាមខែ និងឆ្នាំ ដែលត្រូវបានប្រើដើម្បីគណនាចំណែកតាមសមាមាត្ររបស់អ្នក (ជាសមាមាត្រ) នៃមូលនិធិការផ្សះផ្សារ (ម៉ោងទាំងនេះត្រូវបានរាយនៅលើទំព័រទី 9 នៃការជូនដំណឹងនេះ) និង
3. អ្នកមិនត្រូវបានបង់ប្រាក់សម្រាប់សេវាទាំងនោះ។

ការបែកចែកឡើងវិញ៖ ប្រសិនបើអ្នកមិនដក ឬដាក់ប្រាក់ការផ្សះផ្សារទូទាត់របស់អ្នកទេ ចំណែករបស់អ្នក (និងការប្រាក់ណាមួយលើវា) នឹងមិនបែងចែកឡើងវិញទៅសមាជិកថ្នាក់ការផ្សះផ្សារផ្សេងទៀត ដូចគ្នានេះដែរ ប្រសិនបើសមាជិកថ្នាក់ការផ្សះផ្សារទូទាត់ ផ្សេងទៀតមិនដកសែករបស់ពួកគេ ចំណែករបស់ពួកគេ នឹងត្រូវបែងចែកឡើងវិញទៅថ្នាក់ការផ្សះផ្សារទូទាត់ (រួមមានទាំងអ្នក ប្រសិនបើអ្នកមិនបានជ្រើសចេញ)។ នឹងមានការបែងចែកឡើងវិញពីរ។ ការផ្សះផ្សារណាមួយដែលមិនដកចេញបន្ទាប់ពីការបែងចែកឡើងវិញលើកទីពីរទេ នឹងត្រូវផ្ញើត្រលប់ទៅរដ្ឋ។
ពន្ធលើប្រាក់បៀវត្សរ៍៖ ការផ្សះផ្សារការទូទាត់ប្រាក់របស់អ្នកគឺជាការទូទាត់សងវិញនៃប្រាក់ចំណូល និងពន្ធលើប្រាក់បៀវត្សរ៍ដែលអាចអនុវត្តបាន។ រដ្ឋបាលការផ្សះផ្សារនឹងរាយការណ៍ចំនួនទឹកប្រាក់ទាំងនោះទៅ IRS លើទម្រង់ W-2។

ការផុតកំណត់របស់សហជីព៖ បច្ចុប្បន្នប្រសិនបើអ្នកជាសមាជិករបស់ SEIU 775 ឬធ្លាប់ជាសមាជិកនៅពេលអ្នកបានទទួលប្រាក់ឈ្នួលចុងក្រោយជា IP ម្នាក់ រដ្ឋបាលការផ្សះផ្សានឹងកាត់ 3.2% ពីការទូទាត់របស់អ្នកសម្រាប់ខែដែលអ្នកធ្លាប់ជាសមាជិក SEIU 775 ហើយនឹងផ្ញើប្រាក់នោះទៅសហជីព។

តម្រូវការសម្រាប់ការផ្សះផ្សា៖ ការផ្សះផ្សាការទាមទារឱ្យភ្នាក់ងារសហព័ន្ធដែលដំណើរការ Medicaid បញ្ជាក់ថាវានឹងផ្តល់ការផ្គូផ្គងមូលនិធិសហព័ន្ធសម្រាប់ការទូទាត់ប្រាក់ទាំងអស់។ វាបានផ្តល់ការបញ្ជាក់នោះក្នុងខែធ្នូ ឆ្នាំ 2021។ វាក៏ត្រូវបានតម្រូវថាអង្គនីតិបញ្ញត្តិវ៉ាស៊ីនតោនផ្តល់មូលនិធិយ៉ាងពេញលេញដល់ការផ្សះផ្សា។ អង្គនីតិបញ្ញត្តិធ្វើវានៅក្នុងខែមិនា ឆ្នាំ 2022 ហើយរដ្ឋាភិបាលចុះហត្ថលេខាលើកញ្ចប់ថវិកានៅថ្ងៃទី 31 ខែមិនា ឆ្នាំ 2022។

ជ្រើសរើសចេញ៖ ប្រសិនបើសមាជិកថ្នាក់ច្រើនជាង 3% សម្រេចចិត្តជ្រើសចេញពីការផ្សះផ្សា DSHS អាចចាត់ទុកការផ្សះផ្សាជាមោឃៈ។

**14.** តើការនៅក្នុងថ្នាក់ការផ្សះផ្សាមានផលប៉ះពាល់អ្វីខ្លះ?

លុះត្រាតែអ្នកដកខ្លួនចេញ (ដូចបានពន្យល់នៅក្នុងផ្នែកទី 15 ខាងក្រោម) អ្នកនឹងនៅតែនៅក្នុងថ្នាក់ផ្សះផ្សា។ តុលាការនឹងច្រានចោលករណី "ដោយការរើសអើង" ប្រសិនបើវាអនុម័ត។ ប្រសិនបើវាធ្វើដូច្នេះមែន ទាមទារណាមួយដែលត្រូវបាន ឬអាចត្រូវបានអះអាងនៅក្នុងបណ្តឹងនេះ រួមទាំងដោយអ្នក នឹងត្រូវច្រានចោលជាអចិន្ត្រៃយ៍។ ក្នុងន័យផ្សេងទៀត ដីការបស់តុលាការនឹងដោះលែង និងបញ្ចេញ DSHS ពីការទាមទារសម្រាប់ប្រាក់ឈ្នួលដែលមិនបានបើក ឬម៉ោងបន្ថែម គំរូ ឬការខូចខាតទ្វេដង ថ្លៃសេវាមេធាវី និងការប្រាក់ដែលត្រូវបាន ឬអាចអះអាងដោយភាគីដើមបណ្តឹង ឬថ្នាក់ផ្សះផ្សាដោយផ្អែកលើអង្គហេតុ និងការចោទប្រកាន់នៅក្នុងបណ្តឹងចន្លោះថ្ងៃទី 7 ខែមីនា ឆ្នាំ 2014 និងថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2021 រួមបញ្ចូល ប៉ុន្តែមិនបានកំណត់ឱ្យទាមទារក្រោមច្បាប់ប្រាក់ឈ្នួលអប្បរមារដ្ឋ RCW 49.46, ច្បាប់បង្ខិលប្រាក់ឈ្នួល RCW 49.52, និងកាតព្វកិច្ចសេចក្តីស្មោះត្រង់ និងការដោះស្រាយដោយយុត្តិធម៌ក្នុងកិច្ចសន្យារវាង IP និង DSHS។ នៅពេលការទាមទារ "បានបញ្ចេញ" នោះមានបុគ្គលម្នាក់ស្ថិតក្រោមការដោះលែងមិនអាចប្តឹងនៅពេលក្រោយបានទេ ឬយកមកវិញពីរដ្ឋ ឬភាគីដែលត្រូវបានបញ្ចេញផ្សេងទៀត (ដូចជា DSHS និងភ្នាក់ងាររបស់ពួកគេ) សម្រាប់ការទាមទារណាមួយដែលស្ថិតក្រោមការដោះលែង។

ប្រសិនបើតុលាការអនុម័តការផ្សះផ្សា DSHS ក៏ដោះលែងដើមបណ្តឹង ហើយសមាជិកថ្នាក់ដំណោះដែលមិនបានជ្រើសចេញថ្នាក់ផ្សះផ្សាពីការទាមទារទាំងអស់ដែលត្រូវបាន ឬអាចត្រូវបានអះអាងពាក់ព័ន្ធនឹងបណ្តឹងនេះ រួមបញ្ចូលទាំងការរំលោភលើកាតព្វកិច្ចកិច្ចសន្យាដោយ IP សកម្មភាពកិច្ចសន្យាប្រឆាំងនឹងសមាជិកថ្នាក់ផ្សះផ្សា រួមទាំងសកម្មភាពទាមទារដែលសមាជិកថ្នាក់ដំណោះស្រាយបានធ្វើការម៉ោងដោយគ្មានការអនុញ្ញាតទាក់ទងនឹងច្បាប់អត្ថប្រយោជន៍រួមចំណែក។

## ការដកខ្លួនឯងចេញពីការផ្សះផ្សា

ប្រសិនបើអ្នកចង់រក្សាសិទ្ធិប្តឹងទៅ DSHS ក្នុងនាមជាអ្នកអំពីបញ្ហាច្បាប់នៅក្នុងសំណុំរឿងរបស់អ្នក អ្នកត្រូវតែដកខ្លួនចេញពីថ្នាក់ផ្សះផ្សា។ ដំណើរការដកខ្លួនចេញក៏បានហៅថា "ជ្រើសរើសចេញ" ពីថ្នាក់ផ្សះផ្សា។

**15.** តើខ្ញុំជ្រើសរើសចេញពីការផ្សះផ្សារដោយរបៀបណា?

ប្រសិនបើអ្នកចង់ដកខ្លួនចេញពីការផ្សះផ្សារ អ្នកត្រូវតែផ្ញើសំបុត្រ តាមរយៈសំបុត្រសហរដ្ឋអាមេរិកលំដាប់ទីមួយ ទម្រង់បែបបទបានផ្ដល់ជូន ជាមួយការជូនដំណឹងនេះទៅកាន់

Liang v. State of WA: IP Wage Settlement
c/o JND Legal Administration
PO Box 91373
Seattle, WA 98111

និងរួមទាំងឈ្មោះរបស់អ្នក អាសយដ្ឋានបច្ចុប្បន្ន លេខទូរសព្ទ និងអាសយដ្ឋានអ៊ីមែល។ ដើម្បីឱ្យមានប្រសិទ្ធភាព ការជ្រើសចេញពីការផ្សះផ្សារត្រូវតែបំពេញ ចុះហត្ថលេខា និងបោះត្រាប្រៃសណីយ៍ មិនឱ្យយឺតជាង ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022។

ប្រសិនបើអ្នកប្រគល់សំណើដកខ្លួនពីថ្នាក់ការផ្សះផ្សារមានសុពលភាព និងទាន់ពេលវេលា អ្នកនឹងមិនមានសិទ្ធិទទួលអត្ថប្រយោជន៍ណាមួយនៅក្រោមកិច្ចព្រមព្រៀងដំណោះស្រាយដែលស្នើឡើង ហើយអ្នកនឹងមិនត្រូវបានកំណត់ដោយលក្ខខណ្ឌរបស់វា ឬដោយការដោះលែងទាមទារ ឬការប្រានចោលប្រសិនបើកិច្ចព្រមព្រៀងការផ្សះផ្សារត្រូវបានអនុម័តដោយតុលាការ។ អ្នកក៏ប្រហែលជាអាចប្ដឹង (ឬបន្តប្ដឹង) DSHS នាពេលអនាគត ប្រសិនបើការទាមទាររបស់អ្នកបានកើតឡើងក្នុងលក្ខន្តិកៈនៃដែនកំណត់ដែលអាចអនុវត្តបាន។
ប្រសិនបើអ្នកចង់ដកខ្លួនឯងចេញដើម្បីប្ដឹងបុគ្គលម្នាក់ប្រឆាំងនឹងចុងចោទ អ្នកគួរតែនិយាយទៅកាន់មេធាវីឱ្យបានកាន់តែឆាប់ ព្រោះការទាមទាររបស់អ្នកស្ថិតក្រោមលក្ខន្តិកៈនៃដែនកំណត់។

**16.** ប្រសិនបើខ្ញុំដកខ្លួនចេញ តើខ្ញុំអាចទទួលបានប្រាក់ពីការផ្សះផ្សារឬទេ?

ទេ។ ប្រសិនបើអ្នកជ្រើសរើសចេញ ឬដកខ្លួនចេញ អ្នកនឹងមិនទទួលប្រាក់ណាមួយពីការផ្សះផ្សារទេ។ អ្នកអាចប្ដឹង ឬក្លាយជាផ្នែកបណ្ដឹងផ្សេងគ្នាប្រឆាំងនឹង DSHS ទាក់ទងនឹងការទាមទារដូចគ្នា ស្ថិតក្រោមការការពារដែលអាចអនុវត្តបានទាំងអស់។

ជំទាស់នឹងការផ្សះផ្សារ

អ្នកអាចប្រាប់តុលាការថាអ្នកមិនយល់ស្របនឹងការផ្សះផ្សារ ឬផ្នែកមួយចំនួនរបស់វា។

**17.** តើខ្ញុំប្រាប់តុលាការថាខ្ញុំមិនចូលចិត្តការផ្សះផ្សារដោយរបៀបណា?

ប្រសិនបើអ្នកបន្តនៅក្នុងថ្នាក់ផ្សះផ្សារនេះ អ្នកអាចជំទាស់ទៅនឹងការផ្សះផ្សារបានប្រសិនបើអ្នកមិនចូលចិត្តផ្នែកណាមួយរបស់វា។ អ្នកអាចផ្ដល់ហេតុផលនានាដែលអ្នកគិតថាតុលាការមិនគួរអនុម័តវាឡើយ។ តុលាការនឹងពិចារណាទស្សនៈរបស់អ្នក។ អ្នកអាចជំទាស់ ដោយដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរជាមួយតុលារការត្រឹម ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022 នៅ 2000 Lakeridge Dr. SW, Bldg. 3, Olympia, WA 98502។ អ្នកត្រូវតែផ្ញើតាមសំបុត្រនូវច្បាប់ចម្លងនៃការជំទាស់ជាលាយលក្ខណ៍អក្សររបស់អ្នក ទៅកាន់ទីប្រឹក្សារបស់ដើមបណ្ដឹងនៅអាសយដ្ឋានខាងក្រោម ដោយបិទតែមប្រៃសណីយ៍មិនឱ្យហួសពី ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022។

Jennifer Robbins
Darin M. Dalmat
Sarah E. Derry
Barnard Iglitzin & Lavitt
18 W. Mercer St., Suite 400
Seattle, WA 98119

William McGinty
Dan Judge
Margaret McLean
Sara L. Wilmot
Attorney General's Office
P.O. Box 40124
Olympia, WA 98504

ការជំទាស់របស់អ្នកត្រូវតែមានឈ្មោះរបស់អ្នក អាសយដ្ឋានបច្ចុប្បន្ន លេខទូរសព្ទ និងអាសយដ្ឋានអ៊ីមែល ក៏ដូចជាហេតុផលដែលអ្នកជំទាស់ផងដែរ។ អ្នកអាចបង្ហាញខ្លួនដោយផ្ទាល់នៅសវនាការចុងក្រោយដើម្បីពន្យល់ពីការជំទាស់(ទាទា)របស់អ្នក។ សវនាការនេះនឹងកើតឡើងនៅកាលបរិច្ឆេទ និងពេលវេលាដែលបានបង្ហាញខាងក្រោម។ អ្នកអាចជួលមេធាវីតាមការចំណាយផ្ទាល់ខ្លួនរបស់អ្នក ដើម្បីតំណាងឱ្យអ្នកនៅសវនាការនេះ និងដើម្បីធ្វើការជំទាស់ទៅនឹងការផ្សះផ្សារនេះ។

សមាជិកថ្នាក់ផ្សះផ្សារប៉ុណ្ណោះដែលជំទាស់ទៅនឹងការផ្សះផ្សារដែលបានស្នើសុំតាមរយៈនីតិវិធីទាំងនេះអាចប្តឹងឧទ្ធរណ៍សេចក្តីសម្រេចទាំងឡាយនៅក្នុងករណីនេះ។ ប្រសិនបើអ្នកមិនជំទាស់ត្រឹមកាលបរិច្ឆេទកំណត់ទេ អ្នកមិនអាចជំទាស់នៅពេលក្រោយបានទេ។

**18.** តើវាខុសគ្នាដូចម្តេចខ្លះរវាងការជំទាស់ទៅនឹងការផ្សះផ្សារនេះ និងការដកខ្លួនខ្ញុំខ្លួនឯង?

ការជំទាស់គឺគ្រាន់តែប្រាប់តុលាការថា អ្នកមិនចូលចិត្តអ្វីមួយអំពីការផ្សះផ្សារនេះ។ អ្នកអាចជំទាស់ តែប្រសិនបើអ្នកនៅបន្តក្នុងថ្នាក់ផ្សះផ្សារនេះប៉ុណ្ណោះ។ ការដកខ្លួនឯងចេញ គឺជាការប្រាប់តុលាការថាអ្នកមិនចង់ធ្វើជាផ្នែកនៃថ្នាក់ផ្សះផ្សារនេះទេ។ ប្រសិនបើអ្នកដកខ្លួនឯង អ្នកមិនមានមូលដ្ឋានក្នុងការជំទាស់ទេ ដោយសារតែករណីនេះលែងជះឥទ្ធិពលលើអ្នកទៀតហើយ។

## មេធាវីដែលតំណាងឱ្យអ្នក

**19.** តើអ្នកមានមេធាវីនៅក្នុងករណីនេះដែរទេ?
តុលាការបានសម្រេចថាមេធាវីនៅ Barnard Iglitzin & Lavitt LLP គឺមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការតំណាងឱ្យអ្នក និងសមាជិកថ្នាក់ផ្សះផ្សារទាំងអស់។ មេធាវីទាំងនេះត្រូវបានជ្រើសតាំងជា “ទីប្រឹក្សាថ្នាក់” នៅក្នុងបណ្តឹងនេះ។ ព័ត៌មានបន្ថែមអំពីការងារ និងបទពិសោធន៍របស់មេធាវី គឺអាចរកបាននៅ www.workerlaw.com។ អ្នកនឹងមិនត្រូវបានគិតថ្លៃសម្រាប់មេធាវីទាំងនេះឡើយ។ ប្រសិនបើអ្នកចង់ឱ្យតំណាងដោយមេធាវីផ្ទាល់ខ្លួនរបស់អ្នក អ្នកអាចជួលម្នាក់បានដោយការចំណាយផ្ទាល់ខ្លួនរបស់អ្នក។

**20.** តើមេធាវីនឹងត្រូវបានបង់ប្រាក់ឱ្យដោយរបៀបណា?
ទីប្រឹក្សាថ្នាក់ នឹងស្នើតុលាការឱ្យអនុម័តការបង់ប្រាក់ចំនួន $1,625,000 (1.4% នៃមូលនិធិការផ្សះផ្សារ) សម្រាប់កម្រៃមេធាវីរបស់ពួកគេ និងថ្លៃចំណាយលើបណ្តឹងវិវាទ។ ប្រសិនបើបានអនុម័ត ចំនួនទឹកប្រាក់នេះនឹងត្រូវបានបង់ចេញពីមូលនិធិការផ្សះផ្សារសរុប។ ប្រសិនបើការងារផ្នែកច្បាប់បន្ទាប់ពីថ្ងៃទី 17 ខែកញ្ញា ឆ្នាំ 2021 អស់ថ្លៃច្រើនជាងទីប្រឹក្សាថ្នាក់ដែលបានរំពឹងទុក ពួកគេអាចស្នើសុំតុលាការឱ្យទូទាត់សំណងសម្រាប់កម្រៃមេធាវីបន្ថែម។ DSHS អាចជំទាស់ ប្រសិនបើទីប្រឹក្សាថ្នាក់ធ្វើការស្នើសុំនោះ។ ការផ្សះផ្សារនេះនៅតែអាចមានប្រសិទ្ធភាព ទោះបីជាតុលាការបដិសេធខ្លះ ឬទាំងអស់នៃការស្នើសុំរបស់ទីប្រឹក្សាថ្នាក់សម្រាប់កម្រៃ និងថ្នាក់ចំណាយផ្សេងៗ។

## សវនាការយុត្តិធម៌របស់តុលាការ

**21.** តើសវនាការយុត្តិធម៌មាននៅពេលណា?

នៅ ថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 2022 នាម៉ោង 09:00 ព្រឹក នៅតុលាការកំពូលខោនធី Thurston, 2000 Lakeridge Dr. SW, Bldg. 3, Olympia, WA 98502, តុលាការនឹងដឹកនាំសវនាការមួយដើម្បីកំណត់ថាតើការផ្សះផ្សារដែលបានស្នើសុំគឺមានយុត្តិធម៌ គ្រប់គ្រាន់ និងសមហេតុផលឬអត់ និងថាតើគួរតែត្រូវបានផ្តល់ឱ្យនូវការអនុម័តចុងក្រោយឬយ៉ាងណា។ កាលបរិច្ឆេទ និងពេលវេលានៃសវនាការអនុម័តការផ្សះផ្សារចុងក្រោយអាចប្រែប្រួលដោយគ្មានការជូនដំណឹងជាមុន។ អ្នកគួរតែតាមដានគេហទំព័រការផ្សះផ្សារ www.IPWageSettlement.com សម្រាប់ការអាប់ដេតផ្សេងៗ ឬហៅទូរសព្ទមកលេខឥតគិតថ្លៃរបស់រដ្ឋបាលការផ្សះផ្សារ តាមលេខ 888-964-0102។

**22.** តើខ្ញុំត្រូវតែទៅកាន់សវនាការយុត្តិធម៌នេះ?

ទេ លុះត្រាតែអ្នកបានជំទាស់នឹងការផ្សះផ្សារ។ ប្រសិនបើអ្នកមិនជ្រើសរើសចេញពីការផ្សះផ្សារទេ ទីប្រឹក្សាថ្នាក់អាចតំណាងឱ្យអ្នកបាននៅសវនាការនេះ។ អ្នកទទួលការស្វាគមន៍ចំពោះការមកដោយការចំណាយផ្ទាល់ខ្លួនរបស់អ្នក។ ប្រសិនបើអ្នកផ្ញើការជំទាស់ អ្នកមិនចាំបាច់មកតុលាការទេ។ ដរាបណាអ្នកបានផ្ញើសំបុត្រការជំទាស់ជាលាយលក្ខណ៍អក្សរទាន់ពេល តុលាការនឹងពិចារណាវា។ អ្នកក៏អាចបង់ថ្លៃឱ្យមេធាវីផ្ទាល់ខ្លួនរបស់អ្នកក្នុងការចូលរួមផងដែរ ប៉ុន្តែវាមិនមែនចាំបាច់សម្រាប់ការជំទាស់របស់អ្នកឱ្យត្រូវបានពិចារណានោះទេ។

**23.** តើខ្ញុំអាចនិយាយនៅតុលាការយុត្តិធម៌បានទេ?

ប្រសិនបើអ្នកដាក់ការជំទាស់ទាន់ពេល អ្នកអាចស្នើសុំតុលាការសម្រាប់ការអនុញ្ញាតឱ្យនិយាយនៅតុលាការយុត្តធម៌បាន។ ដើម្បីធ្វើដូច្នោះ សូមរួមបញ្ចូលនូវពាក្យ "ខ្ញុំមានបំណងចង់បង្ហាញខ្លួននៅសវនាការយុត្តិធម៌" នៅក្នុងការជំទាស់ជាលាយលក្ខណ៍អក្សររបស់អ្នក។ សក្ខីភាពរបស់អ្នកនឹងត្រូវបានកំណត់តាមហេតុផលដែលអ្នកបានរួមបញ្ចូលនៅក្នុងការជំទាស់របស់អ្នក។ អ្នកមិនអាចនិយាយនៅសវនាការបានទេ ប្រសិនបើអ្នកដកខ្លួនឯងចេញពីការផ្សះផ្សារនេះ។

## ការទទួលបានព័ត៌មានបន្ថែម

**24.** តើមានព័ត៌មានលម្អិតបន្ថែមអំពីការផ្សះផ្សារនេះដែរទេ?

ការជូនដំណឹងនេះសង្ខេបពីការផ្សះផ្សារដែលបានស្នើសុំ។ ព័ត៌មានលម្អិតបន្ថែមគឺនៅក្នុងកិច្ចព្រមព្រៀងការផ្សះផ្សារ ដែលអ្នកអាចទទួល ដោយហៅទូរសព្ទទៅលេខ 888-964-0102 ឬចូលមើល www.IPWageSettlement.com។

**25.** តើខ្ញុំទទួលបានព័ត៌មានបន្ថែមដោយរបៀបណា?

អ្នកអាចហៅទៅលេខ 888-964-0102; សរសេរទៅអ្នករដ្ឋបាលការផ្សះផ្សារ នៅ៖

Liang v. State of WA: IP Wage Settlement
c/o JND Legal Administration
PO Box 91373
Seattle, WA 98111

ឬចូលមើលគេហទំព័រនៅ www.IPWageSettlement.com, ដែលអ្នកនឹងរកឃើញចម្លើយទៅនឹងសំណួរទូទៅអំពីការផ្សះផ្សារ ទម្រង់បែបបទជ្រើសចេញ បូករួមព័ត៌មានមានប្រយោជន៍ផ្សេងទៀត ដែលទាក់ទងនឹងការផ្សះផ្សារនេះ។

## ព័ត៌មានសង្ខេប ឬចំនួនម៉ោងដែលលៃតម្រូវតាមអត្ថប្រយោជន៍រួមចំណែកនៅក្នុងទិន្នន័យរបស់ DSHS

ចំនួនម៉ោងដែលលៃតម្រូវតាមអត្ថប្រយោជន៍រួមចំណែកដែលបានបង្ហាញនៅក្នុងទិន្នន័យរបស់ DSHS តាមខែ និងឆ្នាំ ដែលត្រូវបានប្រើដើម្បីគណនាចំណែករបស់អ្នកនៃមូលនិធិការផ្សះផ្សារគឺដូចខាងក្រោម៖

[ផ្តល់ជូនដោយអ្នកគ្រប់គ្រង]

## ការស្នើសុំសម្រាប់ការដកខ្លួន

***Liang, et al. v. Wash. State Dep’t of Social and Health Servs., Case No. 20-2-02506-34***

តុលាការកំពូលខោនធី **Thurston**

[ព័ត៌មានទំនាក់ទំនងរបស់អ្នក]

ប្រសិនបើព័ត៌មានដែលបានរាយខាងលើត្រូវបានផ្លាស់ប្តូរ ឬមិនត្រឹមត្រូវ សូមអាប់ដេតព័ត៌មានរបស់អ្នកខាងក្រោម៖

ឈ្មោះ៖ ______________________________________________

អាសយដ្ឋានផ្ញើសំបុត្រ៖ ______________________________________________

______________________________________________

ទូរសព្ទ៖ ______________________________________________

ផ្តល់អាសយដ្ឋានអ៊ីមែលរបស់អ្នក ឬប្រសិនបើអ្នកមិនមានអាសយដ្ឋានអ៊ីមែនទេ ចូរសរសេរ ‘គ្មាន’ ៖

អាសយដ្ឋានអ៊ីមែល៖ ______________________________________________

ដោយការចុះហត្ថលេខាខាងក្រោម និងប្រគល់ត្រឡប់ទម្រង់បែបបទនេះ ខ្ញុំជ្រើសរើសចេញពីការផ្សះផ្សារអត្ថប្រយោជន៍រួមចំណែករបស់ IP។

______________________________ កាលបរិច្ឆេទចុះហត្ថលេខ៖ ______________________

ហត្ថលេខា

ដើម្បីដកខ្លួនអ្នកចេញពីថ្នាក់ផ្សះផ្សារនៅក្នុងករណីនេះ អ្នកត្រូវតែបំពេញ ចុះហត្ថលេខា និងផ្ញើសំបុត្រទម្រង់បែបបទនេះ បិទតែមប្រៃសណីយ៍ មិនឱ្យលើសពីថ្ងៃទី 22 ខែកក្កដា ឆ្នាំ 2022 ទៅកាន់៖

Liang v. State of WA: IP Wage Settlement
c/o JND Legal Administration
PO Box 91373
Seattle, WA 98111